REPRODUCTIVE HEALTH ASSOCIATION OF CAMBODIA

RHAC

# ដំណឹងជ្រើសរើសបុគ្គលិក

សមាគមថែទាំសុខភាពគ្រួសារកម្ពុជា " រ៉ាក់ " គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ កំពុងធ្វើការផ្តោតលើសេវាសុខភាពគ្រួសារ ដែលរួមមានសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សុខភាពមាតា ទារក និងកុមារ ជំងឺរបេង មេរោគអេដស៍/ ជំងឺអេដស៍ និងសុខភាពយុវវ័យ ដែលបាននិងកំពុងអនុវត្តតាមបណ្តាខេត្តក្រុងមួយចំនួនដូចជា រាជធានីភ្នំពេញ ខេត្តព្រះសីហនុ  កំពង់ចាម តាកែវ បាត់ដំបង សៀមរាប ប៉ៃលិន កំពង់ស្ពឺ និងស្វាយរៀង។

សមាគមរ៉ាក់ត្រូវការជ្រើសរើសបុគ្គលិកសំរាប់បំរើការងារកម្មវិធីអេដស៍នៃក្រុមងាយរងគ្រោះ ដូចខាងក្រោម៖

## **អ្នកផ្តល់ប្រឹក្សាសំរាប់ក្រុមបុរសស្រឡាញ់បុរស** (MSM Counselor)

### សំរាប់កម្មវិធីអេដស៍នៃក្រុមងាយរងគ្រោះចំនួន១នាក់នៅខេត្ត បាត់ដំបង

### សង្ខេបភារកិច្ចទទួលខុសត្រូវ៖

ទទួលខុសត្រូវចំពោះការផ្តល់ប្រឹក្សាផ្នែកចិត្តវិទ្យាផ្តល់ការគាំទ្រអ្នកមកធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ចំពោះបុរសរួមភេទជាមួយបុរស ។ ផ្តល់ការអប់រំអំពីសុខភាពបន្តពូជ ការចំលង និងការការពារ ចំពោះជំងឺកាមរោគដល់បុរសស្រឡាញ់បុរស និងធ្វើការទំនាក់ទំនងសំរបសំរួលជាមួយបណ្តាញរបស់អ្នកទាំងនោះ ធ្វើយ៉ាងណាឱ្យពួកគេបានមកទទួលសេវាប្រកបដោយគុណភាពនៅគ្លីនិកសមាគមរ៉ាក់ ។  ជំនួយការជាអ្នកផ្តល់ប្រឹក្សា ដល់អតិថិជនទូទៅ ក្នុងករណីចាំបាច់ ។

### បេក្ខជនត្រូវមានលក្ខណៈសម្បត្តិ៖

សញ្ញាប័ត្រទុតិយភូមិ មានវិញ្ញាបនប័ត្របញ្ជាក់ថាជាអ្នកផ្តល់ប្រឹក្សា ។ ធ្លាប់ចូលរួមការបណ្តុះបណ្តាល សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ។មានបទពិសោធន៍យ៉ាងតិច៣ឆ្នាំជាអ្នកអប់រំបុរសស្រលាញ់បុរស ទាក់ទងទៅនឹងការផ្តល់ប្រឹក្សាជំងឺកាមរោគ រឺអេដស៍ ។ ត្រូវតែមានជំនាញផ្តល់ប្រឹក្សាអេដស៍ ។ មានការយល់ដឹងអំពីធម្មជាតិ អាកប្បកិរិយា និងការប្រព្រឹត្តរបស់ក្រុមបុរសស្រលាញ់បុរស ។ ចំណេះដឹងធ្វើការជាមួយក្រុមបុរសស្រលាញ់បុរស ។ មានជំនាញទំនាក់ទំនងល្អ និងអន្តរបុគ្គល ។ ឥរិយាបទល្អចំពោះ អតិថិជនមានទឹកចិត្តចំពោះតំរូវការរបស់ពួកគេ ។ មានឆន្ទៈធ្វើការតាមម៉ោងបត់បែនដែលត្រូវការដោយករណី ។ យល់ដឹងពីសិទ្ធរបស់អតិថិជន ។

បេក្ខជន ដែលមានចំណាប់អារម្មណ៏ សូមអញ្ជើញដាក់ពាក្យមកការិយាល័យបុគ្គលិកនៅស្នាក់ការកណ្តាលរបស់ សមាគម រ៉ាក់ ផ្ទះលេខ១៤ ផ្លូវលេខ៣១៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឬ ផ្ទះលេខ១៥ ក្រុម ៥៩ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដោយភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប ឯកសារពាក់ព័ន្ធ និងរូបថត (៤ X ៦) ចំនួន១សន្លឹកឬ E-mail to: hr@rhac.org.kh **(Do not attach copies of certificates to the e-mail but bring them to the interview)** ។   ពត៌មានលំអិតសូមទំនាក់ទំនង ទូរស័ព្ទលេខ ០២៣ ៨៨៥ ១៣៥

***ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី 0៤ ខែ ធ្នូ ឆ្នាំ២00៩ វេលាម៉ោង ៥ល្ងាច ។***